**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia

តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

## លោក តំណាងពិសេសអំពាវនាវឱ្យបន្តសើបអង្កេតករណីឃាតកម្ម លើប្រធានសហជីពកម្មករ លោក ជា វិជ្ជា និង ឱ្យដោះលែង លោក ជាម ច័ន្ទនី ជាបន្ទាន់

លោក ភីធីរ លយប្រែកតី តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានប្រកាសបដិសេធមិនទទួលស្គាល់ លទ្ធផលនៃការជំនុំជំរះក្តីចំនួនពីរនៅដើមខែនេះ ដែលនាំឱ្យមានជនជាប់ចោទបីរូប ត្រូវបានកាត់សេចក្តីឱ្យជាប់ពន្ធនាគាររយៈពេលវែង ដោយផ្អែកលើការស៊ើបអង្កេតផ្អែកព្រហ្មទណ្ឌ និងសវនាការរបស់តុលាការ ដែលខ្វះការជឿទុកចិត្ត ។

កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០០៥ តុលាការក្រុងភ្នំពេញ បានកាត់សេចក្តីឱ្យលោក ប៊ន សំណាង និង លោក សុខ សំអឿន ឱ្យ ជាប់ពន្ធនាគារម្នាក់ៗ រយៈពេល ២០ ឆ្នាំ ពីបទឃាតកម្មគិតទុកជាមុន លើរូបលោក ជា វិជ្ជា ប្រធានសហជីពកម្មករ កាលពីថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៤ ។

ការចោទប្រកាន់នេះមិនបានបង្ហាញភស្តុតាងណាមួយដែលភ្ជាប់ការពាក់ព័ន្ធរបស់ចុងចោទទៅនឹងបទឧក្រិដ្ឋនោះឡើយ ហើយក៏មិនបានគោរពតាមគោលការណ៍ជាមូលដ្ឋានស្តីពីការជំនុំជំរះប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ដូចជាគោលការណ៍សន្មត់ថាគ្មានទោស និងភាពមិនលំអៀងរបស់តុលាការ ។

កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៥ តុលាការយោធាបានកាត់ទោសលោក ជាម ច័ន្ទនី តំណាងរាស្ត្រ មកពីគណៈបក្សប្រឆាំង ឱ្យជាប់ពន្ធនាគាររយៈពេល៧ឆ្នាំ ពីបទរៀបចំកងកំលាំងប្រដាប់អាវុធខុសច្បាប់ និងពីបទឆបោក ។ តុលាការបានរាំងមេធាវីចុងចោទមិនឱ្យចោទសួរសាក្សីទាំងអស់ សំរាប់ការចោទប្រកាន់នេះទេ ។ មេធាវីចុងចោទក៏មិនត្រូវបានអនុញ្ញាតឱ្យកោះហៅសាក្សីរបស់ខ្លួនមកបំភ្លឺ ហើយការចោទសួរចុងចោទក៏ត្រូវបានតុលាការរំខាន ដោយមិនមានហេតុផលត្រឹមត្រូវណាមួយឡើយ ។

ការផ្តន្ទាទោសក្នុងបណ្តាករណីចុងក្រោយទាំងនេះ មិនត្រឹមតែផ្តល់ភាពអយុត្តិធម៌ធ្ងន់ធ្ងរដល់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជាការរំលោភបំពានទៅលើនីតិវិធីត្រឹមត្រូវ ដែលបានធានាការពារដោយបទបញ្ញត្តិ ប្រឆាំងនឹងការចាប់ខ្លួននិងការឃុំខ្លួនដោយខុសច្បាប់ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិផ្សេងៗទៀត ដែលប្រទេសកម្ពុជា ជាហត្ថលេខី ។ ការស៊ើបអង្កេត និងការចោទប្រកាន់ ព្រមទាំងការមិនបានគោរពបទដ្ឋានអប្បបរមាដែលធានាឱ្យមានការជំនុំជំរះប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌នេះ ចោទជាបញ្ហាធ្ងន់ធ្ងរយ៉ាងខ្លាំង ដល់ដំណើរការវិវឌ្ឍន៍របស់ប្រទេសកម្ពុជា ឆ្ពោះទៅកាន់នីតិរដ្ឋ ។

សាលក្រមទាំងនេះ ក៏បាននាំមកនូវក្តីកង្វល់ជាថ្មីម្តងទៀត អំពីឯករាជ្យភាពរបស់តុលាការកម្ពុជា ខណៈពេលដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសពីគោលនយោបាយ "កណ្តាប់ដៃដែក " ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅក្នុងស្ថាប័នតុលាការ ។ គោលនយោបាយនេះ បានដាក់ទណ្ឌកម្មដល់មន្ត្រីតុលាការជាច្រើននាក់ ដោយគ្មាននីតិវិធីដាក់វិន័យត្រឹមត្រូវ ហើយបានធ្វើឱ្យខូចខាតថែមទៀត ដល់ឯករាជ្យភាពរបស់តុលាការ ។

លោកតំណាងពិសេសសូមគូសបញ្ជាក់ជាថ្មីម្តងទៀត ពីតំរូវការរបស់ប្រទេសកម្ពុជាថា ត្រូវតែមានប្រព័ន្ធយុត្តិធម៌មួយឯករាជ្យ មិនលំអៀង និងដែលអាចជឿទុកចិត្តបាន ។ លោកបារម្ភថា តុលាការកាន់តែកំពុងត្រូវបាន អង្គនីតិប្រតិបត្តិប្រើប្រាស់ធ្វើជាឧបករណ៍សំរាប់បំបិទមាត់សំលេងប្រឆាំង ។

លោកតំណាងពិសេសអំពាវនាវជាថ្មីម្តងទៀត សូមឱ្យធ្វើការស៊ើបអង្កេតទាំងស្រុង មិនលំអៀង និងដែលអាចជឿទុកចិត្តបាន លើកករណីនៃការសម្លាប់លោក ជា វិជ្ជា និងធ្វើការផ្តន្ទាទោសជនទាំងឡាយ ដែលទទួលខុសត្រូវលើករណីឃាតកម្មនេះទៅតាមច្បាប់ ។

លោកតំណាងពិសេសក៏សូមអំពាវនាវផងដែរ ឱ្យធ្វើការដោះលែងភ្លាមៗ និងដោយគ្មានលក្ខខណ្ឌដល់ លោក ជាម ច័ន្ទនី ព្រមទាំងផ្តល់ជូនលោកវិញ នូវអភ័យឯកសិទ្ធិសភា ។ លោក ជាម ច័ន្ទនី គឺជាជនស៊ីវិលមួយរូប ហើយជនស៊ីវិល មិនស្ថិតនៅក្រោមយុត្តាធិការនៃតុលាការយោធាឡើយ ។

១៦ សីហា ២០០៥

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១០ ផ្លូវលេខ ៣០២ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧